ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នប្រឆាំងអំពើពុករលួយ
**អង្គភាពប្រឆាំងអំពើពុករលួយ**
លេខ ០៥៥/សរ អ.ប.ព.
/២៦

# សេចក្ដីសម្រេច
# ស្ដីពី
# ការទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ នៅខេត្តកោះកុង

## ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- យោងសេចក្ដីសម្រេចលេខ ០២៩/២៦ ស.រ អ.ប.ព. ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦ ស្ដីពីការបង្កើតក្រុមការងារដឹកនាំការងារសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦
- យោងសេចក្ដីជូនដំណឹងលេខ ០០៤/២៦ ស.ជ.ណ អ.ប.ព. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ ស្ដីពីការជ្រើសរើសអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ដែលបានកំណត់អំពីចំនួនអ្នកសង្កេតការណ៍ស្ម័គ្រចិត្តរបស់ អ.ប.ព. នៅតាមរាជធានី-ខេត្តនីមួយៗ អំពីលក្ខខណ្ឌចុះឈ្មោះជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត (មានអាយុចាប់ពី ២១ ឆ្នាំឡើងទៅ - និស្សិត ឬបុគ្គលផ្សេងទៀតក្រៅពីព្រះសង្ឃ (កំពុងគង់ចាំព្រះវស្សា) គ្រូបង្រៀន មន្ត្រីរាជការសាធារណៈ និងអ្នកសារព័ត៌មាន - មិនត្រូវចូលរួមសង្កេតការណ៍ក្នុងមណ្ឌលប្រឡងដែលមានបងប្អូន សាច់ញាតិ ឬមិត្តភក្តិជាបេក្ខជនប្រឡងដែលនេះជាទំនាស់ផលប្រយោជន៍ - ត្រូវឬធ្លាប់បានចូលរួមវគ្គបណ្ដុះបណ្ដាល/កិច្ចប្រជុំផ្សព្វផ្សាយ ស្ដីពីការងារសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ - ត្រូវទាញយកកម្មវិធី Angkor Life មកប្រើប្រាស់សម្រាប់ការជូនដំណឹង និងTelegram សម្រាប់ទំនាក់ទំនងការងារសង្កេតការណ៍ - មានមធ្យោបាយ ធនធាន ពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញការងារសង្កេតការណ៍ស្ម័គ្រចិត្តដោយខ្លួនឯង រួមទាំងមធ្យោបាយធ្វើដំណើរ - គោរពតាមច្បាប់ បទប្បញ្ញត្តិលិខិតបទដ្ឋានគតិយុត្តជាធរមាន ការចាត់តាំង ដឹកនាំ ប្រគល់ភារកិច្ចរបស់ក្រុមដឹកនាំសង្កេតការណ៍ថ្នាក់កណ្ដាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល ជាពិសេសគោរពបានយ៉ាងខ្ជាប់ខ្ជួនបទប្បញ្ញត្តិ សេចក្ដីណែនាំ យល់តួនាទីភារកិច្ចអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត និងអំពីលក្ខខណ្ឌសម្រេចជ្រើសរើសបេក្ខជន (អាទិភាពជ្រើសរើសបេក្ខជនដាក់ពាក្យមុន - និស្សិតកំពុងសិក្សាតាមគ្រឹះស្ថានសិក្សានានា - មិនធ្លាប់ចូលរួមសង្កេតការណ៍ - អាទិភាពនារី - មានអាយុច្រើន)
- យោងតម្រូវការចាំបាច់នៃការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ

# សម្រេច

ប្រការ ១._

**ខេត្តកោះកុង** មានអ្នកដាក់ពាក្យជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចំនួន ៣៥ នាក់ (អ្នកដាក់ពាក្យ)។ សម្រាប់ខេត្តកោះកុង អង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.) មានគម្រោងជ្រើសរើសអ្នកសង្កេតការណ៍ចំនួន ៣៨ នាក់ (ហៅថាអ្នកសង្កេតការណ៍)។

ក្នុងចំណោមអ្នកបានដាក់ពាក្យចំនួន ៣៥ នាក់ អ.ប.ព. ពិនិត្យឃើញថាបានបំពេញគ្រប់តាមលក្ខខណ្ឌ ចំនួន ២១ នាក់។

ប្រការ ២._

ទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ នៅខេត្តកោះកុងចំនួន ២១ នាក់។

| ល.រ. | | គោត្តនាម-នាម | ភេទ |
|---|---|---|---|
| ១.មណ្ឌលបឋមសិក្សាទីរួមខេត្ត | | | |
| 1 | 1 | ឡុង សុវណ្ណារ៉ាក់ | ប |
| 2 | 2 | លី រតនៈ | ប |
| 3 | 3 | ស៊ុម នឿន | ប |
| ២. មណ្ឌលអនុវិទ្យាល័យ ជា ស៊ីម ស្មាច់មានជ័យ | | | |
| 4 | 1 | ទេព លីហៀង | ប |
| 5 | 2 | ប៉ាល់ សុភ័ស្ត | ប |
| 6 | 3 | ហួត ម៉ាលីន | ស |
| ៣. មណ្ឌល វិ.ចប តេជោសែន កោះកុង | | | |
| 7 | 1 | ហ៊ិន ស្រីហ៊ួយ | ស |
| 8 | 2 | ណូយ ប៊ុណ្ណាការ | ប |
| 9 | 3 | សុទ្ធី សុភ័ក្ត្រា | ប |

| ល.រ. | | គោត្តនាម-នាម | ភេទ |
|---|---|---|---|
| 10 | 4 | លឿង ឧលឡោះ | ប |
| 11 | 5 | ងួន សុជម | ស |
| 12 | 6 | ឆិក ចាន់ណេ | ស |
| 13 | 7 | លុកម៉ាន ហៀវហ្សាន | ប |
| 14 | 8 | សុខ ធារ៉ា | ប |
| 15 | 9 | ធុំ សុកន្និកា | ស |
| 16 | 10 | ស៊ុន គីមសួគ៌ | ស |
| 17 | 11 | ទិត្យ ស្រីមុី | ស |
| 18 | 12 | អឿន តាំងលីន | ស |
| 19 | 13 | ហំ សុភឧត្តម | ប |
| 20 | 14 | សាន់ មុស្លីមិន | ប |
| 21 | 15 | ភ្លួង ប្រុស | ប |

ប្រការ ៣._

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តស្ថិតក្រោមការចាត់តាំង ដឹកនាំ និងប្រគល់ភារកិច្ចរបស់ក្រុមការងារដឹកនាំសង្កេតការណ៍ថ្នាក់កណ្ដាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល។

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តត្រូវបំពេញភារកិច្ចឱ្យបានខ្ជាប់ខ្ជួនអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មានជាអាទិ៍ឧបសម្ព័ន្ធ២ ស្ដីពីតួនាទី ភារកិច្ច សិទ្ធិ កាតព្វកិច្ច និងវិន័យ សម្រាប់អ្នកសង្កេតការណ៍ស្ម័គ្រចិត្តនៃសេចក្ដីណែនាំ ស្ដីពីការងារសង្កេតការណ៍របស់អង្គភាពប្រឆាំងអំពើពុករលួយលើដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦។

ប្រការ ៤._

ក្រុមការងារដឹកនាំសង្គតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល សាមីខ្លួនដូចមានក្នុងប្រការ ២ ខាងលើ និងផ្នែកពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០២៦

ទេសរដ្ឋមន្ត្រី

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

កិត្តិនីតិកោសលបណ្ឌិត ឱម_យ៉ិនទៀង

<u>កន្លែងទទួល៖</u>

- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ